## ច្បាប

**ច្បាប់ប្រយុទ្ធប្រឆាំងនិងអំពើហិង្សា និងការរំលោភបំពានលើមនុស្ស** (TVPA) អនុញ្ញាតិអោយអ្នកដែលរួចខ្លួនពីការជួញដូរនៅក្នុងសហរដ្ឋអាមេរិកក្នុងរយៈពេលយ៉ាងហោចណាស់ ០៣ឆ្នាំ ហើយធ្វើការលើកឡើងនូវទោស ដែលអ្នករំលោភបំពានទាំងនោះត្រូវទទួលលើសពីនេះទៀត ច្បាប់នេះក៏ធ្វើជាតារាងនៃសេវាកម្មផ្សេងៗ ដែល អ្នករួចខ្លួនទាំងនោះត្រូវគេផ្តល់សិទ្ធិអោយទទួល ។

TVPA កំណត់អោយបានយ៉ាងត្រឹមត្រូវនូវប្រភេទនៃអ្នកដែលរួចខ្លួនពីការរំលោភបំពានទាំងនោះ ដែលមានសិទ្ធិច្បាប់ ដើម្បីស្នាក់នៅក្នុងសហរដ្ឋអាមេរិក ។ ដើម្បីអោយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលយក **T Visa**
អ្នកដែលច្បាប់ត្រូវ បានគេជួញដូរ ត្រូវតែទទួលបានការរំលោភបំពាន
ដែលមានលក្ខណៈធ្ងន់ធ្ងរ ដែលរួមមាន:

- ការប្រើប្រាស់កំលាំង ការរំលោភបំពាន ឬការគំរាមកំហែង
- សភាពការងារដែលគ្មានការស្ម័គ្រចិត្ត ឬពលកម្មផ្លូវភេទដែលមិនមាន ការស្ម័គ្រចិត្ត ។

**ករណីយ៏លើកលែងចំពោះក្មេង** ឬយុវវ័យ ដែលធ្លាប់ត្រូវបានរំលោភបំពានអ្នកដែលរួចផុតពីការរំលោភបំពាន ដែលមានអាយុក្រោមអាយុ ១៨ឆ្នាំ អាចទទួលបាននូវ T Visa ប្រសិនបើក្មេងទាំងនោះត្រូវបានគេបបួលអោយធ្វើការងារផ្លូវភេទ ដោយមិនចាំបាច់គិតថា តើអ្នកនោះនឹងប្រឈមនឹងការបង្ខំ ការបោក បញ្ឆោត ឬការគំរាមកំហែង នោះទេ ។

**U Visa** មានជូនសំរាប់អ្នកដែលត្រូវបានគេរំលោភបំពានណា ដែលបាន :

- ទទួលរងនូវការរំលោភបំពាន ដែលជាលទ្ធផលឈានទៅរកសកម្មភាពនៃបទឧក្រិដ្ឋ
- ជួយដល់ ឬទំនងថាជាមាន ការជួយដល់ ការធ្វើការស៊ើបអង្កេត ឬការប្តឹងពីបទឧក្រិដ្ឋនោះ ។

សាច់ញាតិរបស់អ្នកដែលធ្លាប់ត្រូវបានគេរំលោភបំពាននោះ ក៏មានសិទ្ធិស្របច្បាប់ ដើម្បីស្នាក់ក្នុងសហរដ្ឋអាមេរិកផងដែរ ។

អ្នកដែលធ្លាប់ត្រូវបានគេរំលោភបំពាននោះ ក៏អាចមានសិទ្ធិច្បាប់ ដើម្បីទទួលបាននូវសេវាកម្មផ្នែកសុខភាព ហើយនឹងសេវាកម្មផ្សេងៗទៀត ទៅតាមកំរិតស្មើគ្នា និងជនភៀសខ្លួនដែរ ។

## AALDEF

**ការធ្វើអោយប្រសើរឡើងនូវសិទ្ធិរបស់ស្រ្តី ហើយនឹងយុវវ័យ ដែលធ្លាប់ត្រូវបានគេរំលោភបំពាន គំរោងការណ៏នេះ** ផ្តល់នូវការបកស្រាយពន្យល់ផ្នែកច្បាប់ដល់ស្រ្តី ហើយនឹងយុវជន ឬយុវនារី ដែលធ្លាប់ត្រូវបានរំលោភបំពាន ដើម្បីធានាអះអាងនូវលទ្ធភាព ដើម្បីឈានទៅរកការទទួលបាននូវសេវាកម្មផ្សេងៗ ដែលមានគុណភាព ។

**AALDEF:** ដោយបានបង្កើតឡើងក្នុងឆ្នាំ ១៩៧៤ មូលនីធិដល់ការអប់រំ និងការការពារផ្នែកច្បាប់ដល់ជនជាតិអាស៊ី សញ្ជាតិអាមេរិក (AALDEF) ការពារនិងពង្រឹងនូវសិទ្ធិប្រជាជន ដែលមកពីអាស៊ី សញ្ជាតិអាមេរិកទាំងអស់ តាមរយៈការប្តឹងផ្តល់ ការគាំទ្រ ហើយនឹងការអប់រំដល់សហគមន៏ស្តីអំពីបញ្ហាមួយចំនួនដូចជាសិទ្ធិរបស់ ជនអន្តោប្រវេសន៏ សិទ្ធិបោះឆ្នោត ភាពយុត្តិធមិផ្នែកសេដ្ឋកិច្ច អំពើហិង្សា ហើយនិង ការប្រព្រឹត្តខុសរបស់ប៉ូលីស ។

**គំរោងការណ៏ ដែលពាក់ព័ន្ធរបស់ AALDEF ដទៃទៀតភាពសមរម្យ និងយុត្តិធមិ**

**ផ្នែកខាងអប់រំ និងសិទ្ធិរបស់យុវវ័យ គំរោងការណ៏នេះ**
ផ្តោតលើលទ្ធភាព ដើម្បីទទួល បាននូវការអប់រំ ដែលប្រើភាសាពីរ
លទ្ធភាពដើម្បីទទួលនូវចំណេះដឹងផ្នែកភាសា ការ
ប្រឆាំងនឹងអំពើហិង្សាមកលើប្រជាជន ដែលមកពីអាស៊ីនៅតាមបណ្តាសាលារដ្ឋនានា
ការរៀបសំណុំរឿងរបស់ក្រុមក្មេង ដែលមានអាយុក្រោម ៩-១១ឆ្នាំ ការធ្វើការ
ប្រលងរបស់សាលា ហើយនឹងសកម្មភាពជាប្រក្រតីផ្សេងៗទៀត ។

**ការធ្វើការការពារប្រឆាំង និងគំនិតផ្តួចផ្តើមនៃការបង្កើតនូវការអន្តោប្រវេសន៏ក្នុងតំបន់ : គំរោងការនេះ** ប្រឹងប្រែង ដើម្បីប្រឆាំងនឹងការបង្កើតឡើងនូវច្បាប់អន្តោប្រវេសន៏ ដែលធ្វើឡើងដោយអង្គភាព រដ្ឋាភិបាលរបស់រដ្ឋ ហើយនឹងរបស់តំបន់ និងការរំលោភលើសិទ្ធិរបស់ជនអន្តោប្រវេសន៏របស់រដ្ឋ តំបន់ តាមរយៈការធ្វើការរៀបចំសហគមន៏ ហើយនឹងការអប់រំ ការគាំទ្រ នយោបាយ និងការប្តឹងផ្តល់ផ្សេងៗ ។

ចំពោះ សំនួរដែលពាក់ព័ន្ធច្បាប់ សូមទាក់ទងមក **Ivy O. Suriyopas**
ដែលជា អ្នកទទួលបន្ទុកផ្នែកខាងយុត្តិធមិ តាមរយៈ
**212.966.5932 X 235** ឬ isuriyopas@aaldef.org.
ចំពោះការផ្តល់យោបល់ សូមទាក់ទងមក **Mabel Tso** តាមរយៈ **X 224** ឬ
mtso@aaldef.org.

## ការធ្វើអោយសិទ្ធិរបស់ស្ត្រី និងយុវវ័យ ដែលធ្លាប់ត្រូវបានគេជួញដូររីកចំរើនទៅមុខ


***មូលនីធិដល់ការអប់រំ និងការការពារផ្នែកច្បាប់ ដល់ប្រជាជនអាស៊ី ដែលមានសញ្ជាតិអាមេរិក***

*99 HUDSON STREET, 12th FL*
*NEW YORK, NY 10013-2815*
ទូរស័ព្ទលេខ :*212.966.5932* ទូរសារលេខ :*212.966.4303*


Trafficking-Khmer

## និយមន័យរបស “Trafficking”

“Trafficking” គឺជាការកេណ្ឌ ការឃុំខ្លួន ឬការទទួលយកមនុស្សតាមរយៈការបង្ខំ ការបោកបញ្ឆោត ការគំរាមកំហែង ដើម្បីយកមកធ្វើជាទាសករ ការងារពលកម្ម ដែលបង្ខិតបង្ខំ ឬការកេងប្រវ័ញ្ច តាមបែបអាពាហ៍ពិពាហ៍ ដែលបង្ខំ ឬឧស្សាហកម្មពាណិជ្ជកម្ម (ដូចជា កសិកម្ម សិប្បកម្ម ការកសាង កិច្ចការតាមភោជនីយដ្ឋាន សោវគតិភាពក្នុងផ្ទះ ឬការងារផ្លូវភេទ ដែលធ្វើជាពាណិជ្ជកម្ម) ។

## សំនួរមួយចំនួនដើម្បីសួរអ្នកដែលរួចផុតពីការជួញដូរដែលជាសកត្តានុពល

- តើអ្នកមកកាន់ហរដ្ឋអាមេរិក ដើម្បីរកការងារធ្វើ ឬក្នុងគោលបំណងតែមួយ ហើយបន្ទាប់មកទើបបានដឹងថា ការងារនោះខុសពីអ្វីដែលគេបានសន្យាមែនទេ?
- តើអ្នកត្រូវបានគេបង្ខំអោយធ្វើការងារមែនទេ? ឧទាហរណ៍ដូចជា
  - ត្រូវបានគេបង្ខំអោយធ្វើជាអ្នកបំរើនៅក្នុងផ្ទះ
  - អោយធ្វើការនៅក្នុងរោងចក្រ ក្រុមហ៊ុន ឬភោជនីយដ្ឋាន
  - ត្រូវគេបង្ខំអោយធ្វើជាអ្នកបំរើផ្លូវភេទ
  - អោយធ្វើកិច្ចការផ្ទះអោយប្តី ឬប្រពន្ធឈ្នួលមែនទេ?
- តើអ្នកត្រូវបានគេប្រាប់ថា អ្នកត្រូវសងបំណុលរបស់អ្នកដោយការធ្វើការងារមែនទេ?
- តើអ្នកចាំបាច់ត្រូវសុំការអនុញ្ញាត ដើម្បីចេញពីផ្ទះ ដើម្បីបរិភោគអាហារ ឬដើម្បីចូលបន្ទប់ទឹកមែនទេ?
- តើមានអ្នកណាម្នាក់ ដកយកលិខិតឆ្លងដែនរបស់អ្នកនិងលិខិតបញ្ជាក់ពីអត្តសញ្ញាណផ្សេងៗទៀតឬទេ?
- តើអ្នក ឬគ្រួសាររបស់អ្នកធ្លាប់ត្រូវបានគេរំលោភបំពាន ឬគំរាមកំហែងដែរឬទេ?

## ពត៏មានមួយចំនួនស្តីអំពីការជួញដូររំលោភបំពានលើមនុស្ស

- ការជួញដូរមនុស្ស គឺខុសពីការរត់ពន្ធមនុស្ស ។ ការរត់ពន្ធមនុស្សគឺជាការឆ្លងកាត់ព្រំដែន អន្តរជាតិដោយគ្មានការត្រួតពិនិត្យ ។ ជនអន្តោប្រវេសន៏ណាដែលត្រូវបានគេនាំចូលសហរដ្ឋអាមេរិក ដោយមិនមានការត្រួតពិនិត្យត្រឹមត្រូវបានបំពានច្បាប់ ចំនែកឯអ្នកដែលត្រូវបានគេ នាំចូលមកសហរដ្ឋអាមេរិកហើយត្រូវបានគេបង្ខំអោយធ្វើការងារ ដែលផ្ទុយពីឆន្ទះរបស់ពួកគេត្រូវបានការពារដោយច្បាប់ ។
- ការជួញដូរមនុស្សមានលក្ខណៈដូចគ្នាទៅនឹងអំពើហឹង្សាក្នុងគ្រួសារ ឈ្មួញជួញដូរមនុស្សទទួលបាននូវការគ្រប់គ្រងលើជនរងគ្រោះ តាមរយៈការរំលោភបំពានលើផ្លូវចិត្ត និង រាងកាយ ។ មនុស្សដែលធ្លាប់ទទួលរងនូវការរំលោភបំពាន ជាធម្មតាពិតជាឯកោ មិនមានឯកសារគ្រប់គ្រាន់ដើម្បីកាន់កាប់កម្មសិទ្ធ ជួបប្រទះនឹងបញ្ហាភាសា ខ្វះខាតធនធាន មានអារម្មណ៏ថាគ្មានអំណាច ហើយមានការភ័យខ្លាច ហេតុការមិនល្អដែលនឹងកើតឡើងនាពេលខាងមុខ ។
- Trafficking (ការរំលោភបំពានមនុស្ស) មានលក្ខណៈធ្ងន់ធ្ងរ ជាការជួញដូរមនុស្សប្រភេទផ្សេងទៀត នៅត្រង់អំពើ ពេស្យាចារ ឬ ការងារបំរើផ្លូវភេទផ្សេងៗទៀត ។ អ្នកដែលធ្លាប់ទទួលរងនូវការរំលោភបំពាន ជាធម្មតាធ្វើការក្នុងរោងចក្រ កសិដ្ឋាន ភោជនីយដ្ឋាន ការសាងសង់ ឬ នៅតាមផ្ទះឯកជន ធ្វើជាអ្នកបំរើក្នុងផ្ទះ ។ អ្នកផ្សេងៗទៀតត្រូវបានគេបង្ខំ អោយធ្វើសកម្មភាពដែលពាក់ព័ន្ធ និងបទឧក្រិដ្ឋ ឬ ត្រូវគេបង្ខំអោយរៀបការ ។
- អ្នកដែលរួចផុតពីការរំលោភបំពាន អាចធ្វើពលរដ្ឋអាមេរិកបាន ។ អ្នកដែលរួចផុតពីការជួញដូររួមមាន ពលរដ្ឋ សញ្ជាតិ ពលរដ្ឋរស់នៅក្នុងសហរដ្ឋអាមេរិកជាអចិន្រ្តៃ ព្រមទាំងជាជនអន្តោប្រវេសន៏ ដែលមិនចាំបាច់ត្រូវការឯកសារអ្វីឡើយ ។
- ការរំលោភបំពានរួមមានទាំងបុរស ស្ត្រី និង កុមារ ។ មនុស្សដែលរួចផុតពីការរំលោភបំពានមានគ្រប់សណ្ឋានទាំងអស់ ។ ចំនួនមនុស្សពាក់កណ្តាលដែលត្រូវបានគេរំលោភបំពានគឺជាកុមារ ហើយ 80% ទៀតគឺជាស្ត្រី ។

## ការធ្វើការសំគាល់មនុស្សដែលធ្លាប់ត្រូវបានគេជួញដូរ

មនុស្សម្នាក់អាចជាជនរងគ្រោះនៃការរំលោភបំពាន ប្រសិនបើចំនុចខាងក្រោមមួយ ឬ ច្រើនជាងមួយពិត :

- មនុស្សនោះជាជនរងគ្រោះនៃការរំលោភច្បាប់ការងារ ។
- និយោជន ឬ គូស្វាមី ភរិយាណាដែលបានគំរាមកំហែងគ្រួសាររបស់ខ្លួន ។
- មនុស្សនោះតែងតែត្រូវ អមដំណើរជាមួយដោយមនុស្សម្នាក់ទៀតដែលទំនងជាមានការគ្រប់គ្រងខ្លាំង ។
- មនុស្សនោះទំនងជាមិនដែលមានអត្តសញ្ញាណណាមួយ ។
- មនុស្សនោះមិនត្រូវបានគេបង់ថ្លៃឈ្នួលធ្វើការ ឬ កំពង់ធ្វើការងារដើម្បីសងបំណុល ។
- ឧស្សាហកម្មជាធម្មតាដែលមានការពាក់ព័ន្ធនិង ការរំលោភបំពានមនុស្សរួមមាន សេវគតិភាព នៅក្នុងផ្ទះ ការងារទេសចរណ៏ ឬ សណ្ឋាគារ ការងារក្នុងរោងចក្រ សេវាកម្មបំរើក្នុងភោជនីយដ្ឋាន ការងារសំណង់ ការងារបំរើផ្លូវភេទ ការងារកសិកម្ម ឬការងារនេសាទ ។

## ប្រភពធនធាន់

- ទូរស័ព្ទទៅ ប៉ូលីសដោយចុចលេខ ៩១១ ។
- ទូរស័ព្ទចុលប្រព័ន្ធ HotLine របស់ AALDEF តាមរយៈលេខ ១.៨00.៩៦៦.៥៩៤៦ ឬ អង្គការស្របច្បាប់ណាមួយផ្សេងទៀតដើម្បីសុំយោបល់ ឬ សេវាកម្មផ្សេងៗ ។
- ទូរស័ពកមកកាន់ស្ថាប័ន យុត្តិធមិរបស់ សហរដ្ឋអាមេរិក ការរំលោភសិទ្ធិមនុស្ស ហើយនិងប្រព័ន្ធទទួលពាក្យ បណ្តឹងស្តីអំពីការកេងកំលាំងការងារលើអ្នកធ្វើការ តាមរយៈលេខ ១.៨៨៨.៤២៨.៧៥៨១ ។
- ទូរស័ព្ទមក ស្ថាប័នផ្នែកខាងសុខភាព ហើយនឹង សេវាកម្មផ្សេងៗដល់មនុស្សពតិមានស្តីអំពី ការរំលោភបំពាន លើមនុស្ស និងប្រព័ន្ធ Hot Line សំរាប់ការ ផ្តល់យោបល់ តាមរយៈលេខ 1.888.373.7888 ។